# ព្រឹត្តិបត្រព័ត៌មាន ការប្រែប្រួលអាកាសធាតុ

#១១

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
នាយកដ្ឋានប្រែប្រួលអាកាសធាតុ

តុលា-ធ្នូ
២០១៧


## គោលនយោបាយប្រែប្រួលអាកាសធាតុ និងការអនុវត្ត

### ភាពជាដៃគូជាមួយស្ថាប័នសិក្សាលើផ្នែកប្រែប្រួលអាកាសធាតុ

នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានការគាំទ្រពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា កំពុងបង្កើតនិងប្រតិបត្តិការក្របខណ្ឌគ្រប់គ្រងចំណេះដឹងនិងព័ត៌មានប្រែប្រួលអាកាសធាតុ។ ភាពជាដៃគូលើផ្នែកប្រែប្រួលអាកាសធាតុគឺជាសមាសភាគចម្បងមួយដែលត្រូវអនុវត្តជាមួយសាកលវិទ្យាល័យ គ្រឹះស្ថានសិក្សានិងស្រាវជ្រាវដើម្បីកសាងសមត្ថភាពនិងចំណេះ-ដឹងស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

ក្នុងន័យនេះនាយកដ្ឋានប្រែប្រួលអាកាសធាតុនិងអគ្គលេខាធិការដ្ឋាន កំពុងរៀបចំបង្កើតកិច្ចព្រមព្រៀងរយៈពេលវែងជាមួយស្ថាប័នសិក្សានិងស្រាវជ្រាវនៅកម្ពុជា ដើម្បីលើកកម្ពស់ចំណេះដឹងនិងពង្រឹងការអភិវឌ្ឍគោលនយោបាយផ្អែកលើភស្តុតាងពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព។

អគ្គលេខាធិការដ្ឋានបានបង្កើតភាពជាដៃគូផ្លូវការជាមួយគ្រឹះស្ថានសិក្សាចំនួនបួន ដើម្បីជំរុញការសិក្សាស្រាវជ្រាវនិងកសាងសមត្ថភាពពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព រួមបញ្ចូលទាំងការប្រែប្រួលអាកាសធាតុ ជីវៈចម្រុះ សេដ្ឋកិច្ចបៃតង និងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។ គ្រឹះស្ថានទាំងបួននោះរួមមាន សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាលាជាតិកសិកម្មព្រែកលៀប និងសាកលវិទ្យាល័យមានជ័យ បានចុះអនុស្សរណៈយោគយល់ស្តីពីកិច្ចសហ

តទៅទំព័រទី១




*អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនិងស្ថាប័នសិក្សាចំនួនបួន ចុះហត្ថលេខាលើអនុស្សរណៈនៃយោគយល់ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យអភិវឌ្ឍន៍ដោយចីរភាព នាថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧*

## កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ

### ជំហររបស់ប្រទេសកម្ពុជាសម្រាប់COP23 នៃ UNFCCC

សន្និសីទបណ្តាភាគីលើកទី២៣ (COP23) ដែលប្រព្រឹត្តទៅនៅទីក្រុងបោន ប្រទេសអាល្លឺម៉ង់ បានចាប់ផ្តើមពីថ្ងៃទី 06 ដល់ ១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្រោមការដឹកនាំរបស់ប្រទេសហ្វីជី។ សន្និសីទនេះបានប្រមូលផ្តុំសមាជិករដ្ឋទាំងអស់ចំនួន១៩៥ប្រទេស សរុប១៦០២៥នាក់ រួមបញ្ចូលទាំងអង្គការក្រៅរដ្ឋាភិបាលនិងតំណាងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុជាសកល។ ប្រទេសហ្វីជីបានគូសបញ្ជាក់ពីចក្ខុវិស័យក្នុងនាមជាប្រធានថា ត្រូវមានតម្លាភាព រួមបញ្ចូលទាំងអស់គ្នា ជំរុញកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងពន្លឿនសកម្មភាពអាកាសធាតុសម្រាប់សង្គមដែលងាយរងគ្រោះ។

គណៈប្រតិភូកម្ពុជាចំនួន២២រូប ដឹកនាំដោយក្រសួងបរិស្ថានរួម ជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចូលរួមក្នុងសន្និសីទនេះ ដើម្បីបង្ហាញពីជំហររបស់ប្រទេសក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

តទៅទំព័រទី៣

## មាតិកាព័ត៌មាន


គោលនយោបាយប្រែប្រួលអាកាសធាតុនិងការអនុវត្ត
- ភាពជាដៃគូជាមួយស្ថាប័នសិក្សាលើផ្នែកប្រែប្រួលអាកាសធាតុ ........................ ១
- ការជ្រើសរើសអាទិភាពគោលនយោបាយស្រាវជ្រាវផ្នែកប្រែប្រួលអាកាសធាតុ ....... ២
- ការប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវក្របខណ្ឌហិរញ្ញប្បទានផែនការជាតិបន្សាំនឹងការប្រែប្រួលអាកាស ..................... ៣

កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ
- ជំហររបស់ប្រទេសកម្ពុជាសម្រាប់COP23 នៃUNFCCC .................................. ១

សម្លេងពីមូលដ្ឋាន
- ភាពងាយរងគ្រោះនៃការចិញ្ចឹមជីវិត របស់ឃុំចំនួន៤នៅតំបន់រាំមសារស្ទឹងត្រែង ....... ៤
- ការច្នៃប្រឌិតថ្មីនៃឡជីវឧស្ម័នខ្នាតមធ្យមសម្រាប់បរិស្ថានឆ្លាត ........................... ៥

ការចេញផ្សាយបន្ទាប់ .................................. ៦
ឯកសារបោះពុម្ពផ្សាយនាពេលខាងមុខ ........... ៦
ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ ............. ៦


## ចំណាប់អារម្មណ៍របស់និពន្ធនាយក

*សូមគោរពប្រិយមិត្តអ្នកអាន យើងខ្ញុំសូមស្វាគមន៍ចំពោះការអានព្រឹត្តិបត្រព័ត៌មានការប្រែប្រួលអាកាសធាតុ។ ព្រឹត្តិបត្រព័ត៌មាននេះចេញផ្សាយរៀងរាល់ត្រីមាស ដើម្បីឆ្លុះបញ្ចាំងអំពីការអភិវឌ្ឍគោលនយោបាយអាកាសធាតុថ្មីៗនៅកម្ពុជា ព្រមទាំងបច្ចុប្បន្នភាពការងារជាច្រើនដែលអនុវត្តក្រោមអណត្តិនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ដោយឡែកក្នុងត្រីមាសទី២និងទី៤នៃឆ្នាំនីមួយៗ យើងនឹងបន្ថែមការចែករំលែកបទពិសោធន៍សំខាន់ៗដែលអនុវត្តដោយអង្គការដៃគូនិងសហគមន៍នានាឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ យើងខ្ញុំសង្ឃឹមថាប្រិយមិត្តអ្នកអាននឹងផ្តល់ធាតុចូលដូចជាការផ្តល់មេរៀនល្អៗនិងករណីសិក្សានានាដែលនាំឱ្យព្រឹត្តិបត្រនេះជោគជ័យ៕*

## ក្រុមការងាររៀបចំ និងត្រួតពិនិត្យ


*ព្រឹត្តិបត្រព័ត៌មាននេះ ត្រូវបានរៀបចំកែសម្រួល និងផលិតដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានជំនួយបច្ចេកទេសពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា៕*

# គោលនយោបាយប្រែប្រួលអាកាសធាតុ និងការអនុវត្ត

## ភាពជាដៃគូជាមួយស្ថាប័នសិក្សាលើផ្នែកប្រែ...

*តពីទំព័រទី១*

ប្រតិបត្តិការក្នុងវិស័យអភិវឌ្ឍន៍ដោយចីរភាព នៅក្រសួងបរិស្ថាន នាថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៧។

នេះគឺជាលើកដំបូងដែលក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពបានបង្កើតកិច្ចព្រមព្រៀងផ្លូវការរយៈពេលវែងជាមួយស្ថាប័នសិក្សា ដើម្បីធ្វើការកែលម្អការអប់រំ ការយល់ដឹង ចំណេះដឹង ព្រមទាំងសមត្ថភាពមនុស្សនិងស្ថាប័ននៅក្នុងវិស័យអភិវឌ្ឍន៍ដោយចីរភាព។ ទម្រង់នៃកិច្ចសហប្រតិបត្តិការ រួមមាន ការស្រាវជ្រាវផ្អែកលើគោលនយោបាយ ការធ្វើឱ្យប្រសើរឡើងនូវការផ្លាស់ប្តូរទិន្នន័យ ព័ត៌មាន និងចំណេះដឹងក្នុងចំណោមអ្នកសិក្សា អ្នករៀបចំគោលនយោបាយ និងអ្នកអនុវត្ត ព្រមទាំងផ្តល់ឱកាសសម្រាប់ពង្រឹងសមត្ថភាពនិស្សិតនិងសាស្ត្រាចារ្យ។

កិច្ចសហប្រតិបត្តិការនេះឆ្លុះបញ្ចាំងអំពីតួនាទីនិងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពក្នុងការ លើកកម្ពស់ការអភិវឌ្ឍដោយនិរន្តរភាព និងកសាងសមត្ថភាពលើការច្នៃប្រឌិតផ្នែកប្រែប្រួលអាកាសធាតុ ការស្រាវជ្រាវ និងការយល់ដឹង សំដៅសង្រួមគម្លាតរវាងវិទ្យាសាស្ត្រនិងគោលនយោបាយ។ អគ្គលេខាធិការដ្ឋាន គ្រោងនឹងបង្កើនកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យចំនួនពីរបន្ថែមទៀតនៅក្នុងឆ្នាំ២០១៨៕



*អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ប្រគល់សៀវភៅសន្ទានុក្រមការប្រែប្រួលអាកាសធាតុជូនសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ*

## ការជ្រើសរើសអាទិភាពគោលនយោបាយស្រាវជ្រាវផ្នែកប្រែប្រួលអាកាសធាតុ

ផ្អែកតាមផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ការស្រាវជ្រាវចំណេះដឹង និងច្នៃប្រឌិត គឺជាផ្នែកសំខាន់មួយនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ជាចាំបាច់ យើងត្រូវធ្វើការកំណត់អាទិភាពសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុច្បាស់លាស់ ដើម្បីជួយសម្រួលនិងកំណត់ទិសដៅនៃកិច្ចខិតខំប្រឹងប្រែងទាំងពេលបច្ចុប្បន្ននិងអនាគតក្នុងការស្រាវជ្រាវលើផ្នែកប្រែប្រួលអាកាសធាតុ ដែលអនុវត្តដោយគ្រឹះស្ថានសិក្សាស្រាវជ្រាវ ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។ លទ្ធផលនៃការស្រាវជ្រាវទាំងនេះ នឹងក្លាយជាមូលដ្ឋានចំណេះដឹងប្រែប្រួលអាកាសធាតុកាន់តែរឹងមាំសម្រាប់គាំទ្រដល់ការសម្រេចចិត្ត និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តវិធានការឆ្លើយតបដល់មូលដ្ឋាន។

ការពិភាក្សាស៊ីជម្រៅអំពីអាទិភាពនៃការស្រាវជ្រាវពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ បានធ្វើឡើងនៅក្នុងសិក្ខាសាលាចែករំលែកចំណេះដឹង នៅខេត្តសៀមរាប កាលពីថ្ងៃទី៥-៦ ខែធ្នូ ឆ្នាំ២០១៧ រៀបចំដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុ/កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។ ក្រោមប្រធានបទ "ការស្រាវជ្រាវនិងការអនុវត្តក្នុងប្រទេសកម្ពុជា" អ្នកស្រាវជ្រាវ អ្នករៀបចំគោលនយោបាយ និងអ្នកអនុវត្ត បានចែករំលែកបេតគំហើញថ្មីៗនិងមេរៀនទទួលបានពីការសិក្សាស្រាវជ្រាវកន្លងមក ដើម្បីបង្កើតជាអាទិភាពរួមមួយសម្រាប់ស្រាវជ្រាវទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ កិច្ចពិភាក្សាបានធ្វើឡើងដោយយកអាទិភាពនៃការស្រាវជ្រាវនិងការច្នៃប្រឌិតដំបូងដែលរៀបចំដោយអគ្គលេខាធិការដ្ឋាននៅឆ្នាំ២០១៥ ហើយអង្គសិក្ខាសាលាបានរកឃើញអាទិភាពស្រាវជ្រាវគោលនយោបាយប្រែប្រួលអាកាសធាតុសរុបចំនួន ១៨ (ដូចមាននៅក្នុងប្រអប់)។

កិច្ចពិភាក្សានេះនឹងប្រើជាធាតុចូលសម្រាប់រៀបចំរបៀបវារៈស្រាវជ្រាវថ្នាក់ជាតិគាំទ្រដល់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាតិដោយផ្អែកលើអាទិភាពគោលនយោបាយជាតិនិងគម្លាតស្រាវជ្រាវ។ ជំហាន និងអនុសាសន៍បន្ទាប់សម្រាប់អនុវត្តនាពេលអនាគតរួមមាន៖

- បង្កើតរបៀបវារៈស្រាវជ្រាវថ្នាក់ជាតិ គាំទ្រដល់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិដោយផ្អែកលើអាទិភាពគោលនយោបាយជាតិនិងគម្លាតដែលមានស្រាប់។

**សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់និងការកាត់បន្ថយ**

១. ការស្រាវជ្រាវនិងការអភិវឌ្ឍបច្ចេកវិទ្យាដែលចំណាយថ្លៃទាប បញ្ចេញកាបូនទាប និងសមស្រប សម្រាប់ថាមពល ឧស្សាហកម្ម និងគ្រប់គ្រងសំណល់
២. ការសិក្សាភាពមិនប្រាកដប្រជានៃការកាត់បន្ថយកាបូនក្នុងការប៉ាន់ប្រមាណការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHGs)ថ្នាក់ជាតិ និងការដកចេញពីការបញ្ចេញសំខាន់ៗ។
៣. ការកែលម្អទិន្នន័យសកម្មភាពនិងមេគុណបញ្ចេញសម្រាប់ប្រភពសំខាន់ៗនៃសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ
៤. ការសិក្សាវាយតម្លៃអំពីស្តង់ដារអគារបៃតងនិងទីក្រុងស្អាតទៅលើការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់/សមត្ថភាពធន់ទ្រាំ

**បន្សាំ**

៥. ភាពធន់អាកាសធាតុនៃប្រព័ន្ធផលិតកម្មស្បៀងសម្រាប់បង្កើនសន្តិសុខស្បៀង
៦. ការសិក្សាវាយតម្លៃអំពីហានិភ័យសុខាភិបាលពាក់ព័ន្ធនឹងគោលនយោបាយចាប់ពីរយៈពេលខ្លីដល់រយៈពេលមធ្យម និងឥទ្ធិពលជាបន្តបន្ទាប់ (ដោយផ្តោតលើក្រុមងាយរងគ្រោះដែលប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ)
៧. ការស្វែងយល់អំពីតួនាទីរបស់កម្មវិធីគាំពារសង្គមនិងការផ្តល់ព័ត៌មានជាមុនក្នុងការកាត់បន្ថយភាពងាយរងគ្រោះទៅនឹងវិសមរូបនិងការប្រែប្រួលអាកាសធាតុ (រួមបញ្ចូលទាំងការវិភាគយេនឌ័រ)
៨. ការបង្កើតវិធីសាស្ត្រពីក្រោមទៅលើដែលមានការចូលរួម និងបន្សុំាផ្អែកលើសហគមន៍/ប្រព័ន្ធអេកូឡូស៊ី
៩. ការបង្កើតវិធីសាស្ត្រវាយតម្លៃបច្ចេកវិទ្យាបន្សុំានិងការគណនាថ្លៃចំណាយវិធានការបន្សុំាសម្រាប់ការធ្វើផែនការថ្នាក់មូលដ្ឋាន
១០. បរិមាណកម្មសេវាកម្មប្រព័ន្ធអេកូឡូស៊ី - វិភាគទានជាវិធីសាស្ត្រដើម្បីបង្កើតប្រព័ន្ធគណនេយ្យធនធានធម្មជាតិក្នុងបរិបទប្រែប្រួលអាកាសធាតុ
១១. ឥទ្ធិពលរបស់អែលនីណូទៅលើទឹកនិងអនាម័យនៅកម្ពុជា
១២. ការកំណត់បច្ចេកវិទ្យា/វិធីសាស្ត្រដើម្បីកាត់បន្ថយការបាត់បង់ទឹកសម្រាប់ប្រព័ន្ធធារាសាស្ត្រខ្នាតមធ្យម
១៣. ការសិក្សាអំពីលទ្ធភាពទឹកក្រោមដីសម្រាប់ការប្រើប្រាស់យូរអង្វែង
១៤. វិធីសាស្ត្រស្រាវជ្រាវនិងវិធីសាស្ត្រវាយតម្លៃភាពងាយរងគ្រោះ និងការវិភាគថ្លៃបន្សុំា/ថ្លៃដើម្បី-ផលប្រយោជន៍

**ការអភិវឌ្ឍភាពធន់ដែលបញ្ចេញកាបូនទាប**

១៥. ការយល់ដឹងអំពីតួនាទីនៃការរៀបចំផែនការប្រើប្រាស់ដីក្នុងការបន្សុំានឹងការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយ
១៦. ការយល់ដឹងអំពីភាពធន់ទីក្រុង - អនុសាសន៍តាមបែបបច្ចេកទេសនិងគោលនយោបាយសម្រាប់អភិវឌ្ឍលំនៅដ្ឋានបញ្ចេញកាបូនទាប (រួមបញ្ចូលទាំង អភិបាលកិច្ច ការគ្រប់គ្រង ការធ្វើផែនការ និងប្លង់រចនា)
១៧. ការសិក្សាវាយតម្លៃការគ្រប់គ្រងការប្រើប្រាស់ដីប្រកបដោយនិរន្តរភាព
១៨. ការសិក្សាវាយតម្លៃអំពីស្តង់ដារអគារបៃតងនិងទីក្រុងស្អាតទៅលើការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់/សមត្ថភាពធន់ទ្រាំ

- ប្រមូលផ្តុំលទ្ធផលស្រាវជ្រាវនានាដែលមានស្រាប់ពាក់ព័ន្ធនឹងអាទិភាពដែលបានរកឃើញខាងលើ។
- អនុវត្តភាពជាដៃគូផ្នែកប្រែប្រួលអាកាសធាតុជាមួយសាកលវិទ្យាល័យ ដើម្បីកំណត់យន្តការល្អសម្រាប់ស្រាវជ្រាវនៅកម្ពុជា
- លើកកម្ពស់ប្រព័ន្ធគ្រប់គ្រងចំណេះដឹងដើម្បីឱ្យលទ្ធផលស្រាវជ្រាវទាំងអស់ត្រូវបានប្រើប្រាស់។

*របាយការណ៍សិក្ខាសាលា មាននៅក្នុង តំណភ្ជាប់ ឬ www.camclimate.org.kh*

## ការប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវក្របខណ្ឌហិរញ្ញប្បទានផែនការជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ

ក្របខណ្ឌហិរញ្ញប្បទានផែនការជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងផែនការបន្សាំ ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ ដោយមានតំណាងក្រសួងបរិស្ថាន ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ សាកលវិទ្យាល័យ និងប្រព័ន្ធផ្សព្វផ្សាយ សរុប១១០នាក់ នៅសណ្ឋាគារភ្នំពេញ។

ក្របខណ្ឌនេះមានគោលបំណងដើម្បីបង្កើនលទ្ធភាពកម្ពុជាក្នុងការទទួលបានហិរញ្ញប្បទានបន្ថែម និងវិភាគអំពីតម្រូវការហិរញ្ញវត្ថុនិងគម្លាតដែលមាន។ ឯកសារនេះពិនិត្យលើទិដ្ឋភាពនៃហិរញ្ញវត្ថុអាកាសធាតុអន្តរជាតិ ផ្តល់អនុសាសន៍រយៈពេលមធ្យមនិងរយៈពេលវែង ក៏ដូចជារយៈពេលខ្លីសម្រាប់សកម្មភាពប្រែប្រួលអាកាសធាតុអាទិភាពចំនួន៤០។

សកម្មភាពអាទិភាពវិភាគចេញពីផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យសរុប ចំនួន៤០ ត្រូវបានបែងចែកជាបីក្រុម។ អនុសាសន៍សំខាន់ៗនៅក្នុងក្របខណ្ឌហិរញ្ញប្បទានផែនការជាតិបន្សាំ រួមមាន៖

- សកម្មភាពអាទិភាពគួរបន្តអនុវត្តតាមបែបវិស័យឬកម្មវិធីជាជាងគម្រោងតូចៗ។




*ឯកឧត្តម អ៊ាង សុផល្លែត អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន ប្រគល់សៀវភៅជូនតំណាងក្រសួងបរិស្ថាន នាថ្ងៃទី១២ ខែតុលាឆ្នាំ២០១៧ នៅសណ្ឋាគារភ្នំពេញ*

- តម្រូវការបន្តពង្រឹងសមត្ថភាពរៀបចំគម្រោងនិងថវិកា
- ឃ្លាំងថ្នាក់ជាតិស្តីពីវិទ្យាសាស្ត្រអាកាសធាតុ/ចំណេះដឹង/ការអភិវឌ្ឍត្រូវការរៀបចំបន្ថែមទៀត
- ពង្រឹងការសម្របសម្រួលការបញ្ជ្រាបភាពធន់ទ្រាំនឹងអាកាសធាតុតាមវិស័យទៅក្នុងផែនការ និងថវិការបស់ក្រសួង
- បង្កើនការរួមបញ្ចូលទិដ្ឋភាពយេនឌ័រឆ្លើយតបនឹងអាកាសធាតុ

*តទៅទំព័រទី៤*

# កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ

## ជំហររបស់ប្រទេសកម្ពុជាសម្រាប់COP23 ...

*តពីទំព័រទី១*

កម្ពុជាមានការប្តេជ្ញាចិត្តខ្ពស់ដោះស្រាយការប្រែប្រួលអាកាសធាតុ ដោយបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុទាន់ពេលវេលា ហើយបានបញ្ជូនផែនការចូលរួមចំណែករបស់កម្ពុជាក្នុងអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(NDC)ផងដែរ។ កម្ពុជាបានអំពាវនាវដល់គ្រប់ភាគីទាំងអស់ផ្តល់នូវការគាំទ្រដល់រាជរដ្ឋាភិបាល ដើម្បីសម្រេចទិសដៅផែនការរបស់ខ្លួនដែលថានឹងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ឱ្យបាន ២៧%ត្រឹមឆ្នាំ២០៣០ និងសន្យាបង្កើនចំនួនព្រៃឈើនៅក្នុងប្រទេសឱ្យបានចន្លោះពី ៤៧ ទៅ ៦០%។ វិធានការសំខាន់ៗដែលកម្ពុជាបានចូលរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសកល រួមមាន ១) ការកសាងសមត្ថភាពស្ថាប័ន ២) ការរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ៣) ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ (៤) ការកៀរគរធនធានសម្រាប់សកម្មភាពអាកាសធាតុ ៥) ការអភិវឌ្ឍគោលនយោបាយថាមពលកកើតឡើងវិញនិងប្រសិទ្ធភាពថាមពល ៦) ការអភិរក្សព្រៃឈើ និង ៧) ការអនុវត្តគម្រោងនានាសំដៅកសាងភាពធន់របស់សហគមន៍ និងបរេចិញ្ចឹមជីវិតដែលមាននិរន្តរភាព។

ប្រធានCOP២៣ បានអំពាវនាវឱ្យរដ្ឋាភិបាលធំៗគ្រប់លំដាប់ថ្នាក់ សង្គមស៊ីវិល សហគមន៍សាសនា វិស័យឯកជន បុរស និងស្ត្រីទូទៅនៅទូទាំងពិភពលោកសាមគ្គីគ្នាធ្វើសកម្មភាពអាកាសធាតុ រួបរួមគ្នាដើម្បីសកម្មភាពអាកាសធាតុឱ្យកាន់តែស៊ីជម្រៅ រហ័ស និងរួមគ្នា។ លទ្ធផលសំខាន់ៗនិងសេចក្តីសម្រេចចិត្តរបស់COP23 មានគូសបញ្ជាក់នៅក្នុងប្រអប់។




*ឯកឧត្តម ឃុត ចាន់ដារ៉ា អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានប្រតិភូកម្ពុជា ធ្វើសេចក្តីថ្លែងការណ៍ប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅប្រទេសអាល្លឺម៉ង់*

លទ្ធផលCOP23៖ សេចក្តីសម្រេចបានមហិច្ឆតាមុនឆ្នាំ២០២០

- ជំរុញការអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ ដោយCOP24 ខែធ្នូ ឆ្នាំ២០១៨
- ការដាក់ឱ្យដំណើរការកិច្ចសន្ទនាTalanoa២០១៨ដែលអនុញ្ញាតឱ្យបណ្តាប្រទេស ឬរដ្ឋភាគី ចែករំលែកបទពិសោធ និងបង្ហាញពីការអនុវត្តល្អៗ ដើម្បីបង្កើនមហិច្ឆតា រួមបញ្ចូលទាំងសកម្មភាពត្រៀមឆ្នាំ២០២០ សម្រាប់ការចូលរួមចំណែករបស់ជាតិ(NDCs) តាមរយៈរបាយការណ៍ដែលត្រូវបញ្ជូននៅCOP24
- ស្នើសុំប្រទេសជាសមាជិកពិធីសារក្យូតូ ផ្តល់សច្ចាប័នលើវិសោធនកម្មទីក្រុងដូហាស្តីពីពិធីសារក្យូតូឱ្យបានឆាប់តាមដែលអាចធ្វើបាន
- រៀបចំកិច្ចប្រជុំដើម្បីប្រមូលព័ត៌មានអំពីការអនុវត្តនិងមហិច្ឆតាមុនឆ្នាំ ២០២០ ស្តីពីកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយនិងការគាំទ្រផ្នែកហិរញ្ញវត្ថុ បច្ចេកវិទ្យា និងការកសាងសមត្ថភាពនៅក្នុងCOP24 និង COP25 ។
- នៅក្រោម "ចលនាហ្វីជីសម្រាប់អនុវត្ត" ភាគីនានាបានសម្រេចចិត្តវិភាជថវិកាសម្រាប់អនុវត្តកិច្ចព្រមព្រៀងប៉ារីស ដើម្បីរៀបចំវេទិកាសហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិច បង្កើតផែនការសកម្មភាពយេនឌ័រសិក្សាពិនិត្យមូលនិធិបន្សាំ និងអភិវឌ្ឍសមត្ថភាពនិងលើកកម្ពស់ការយល់ដឹងអំពីការបាត់បង់និងការខូចខាត។
- COP24 នឹងប្រព្រឹត្តនៅដើមខែធ្នូ ឆ្នាំ២០១៨ នៅប្រទេសប៉ូឡូញ។

# គោលនយោបាយប្រែប្រួលអាកាសធាតុ និងការអនុវត្ត

## ការប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ ...

*តពីទំព័រទី៣*

យោងតាមអនុសាសន៍នៃក្របខណ្ឌនេះ និងកិច្ចពិភាក្សាជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព កម្មវិធីត្រៀមហិរញ្ញវត្ថុអាកាសធាតុនឹងគាំទ្រក្រសួងមួយដែលងាយរងគ្រោះនឹងការប្រែប្រួលអាកាសធាតុជាងគេចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីហិរញ្ញវត្ថុអាកាសធាតុ ដោយប្រើសកម្មភាពអាទិភាព ដើម្បីរៀបចំសំណើគម្រោងរឹងមាំជាងមុនក្នុងការស្វែងរកមូលនិធិអន្តរជាតិ។ ទោះជាយ៉ាងណាក្តី កិច្ចខិតខំប្រឹងប្រែងបន្ថែមនិងប្រកបដោយនិរន្តរភាព ចាំបាច់ត្រូវការភាគីពាក់ព័ន្ធទាំងក្នុងស្រុកនិងអន្តរជាតិ ដើម្បីអនុវត្តអនុសាសន៍នៅក្នុងក្របខណ្ឌនេះ។

ក្របខ័ណ្ឌហិរញ្ញប្បទានផែនការជាតិបន្សាំត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានការគាំទ្រពីកម្មវិធីត្រៀមលក្ខណៈហិរញ្ញវត្ថុអាកាសធាតុ( CF Ready )។ កម្មវិធី CF Ready អនុវត្តដោយកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់( GIZ ) ក្រោមកិច្ចសហប្រតិបត្តិការនិងហិរញ្ញប្បទានដោយUSAID ដើម្បីបង្កើតផែនការជាតិបន្សាំ( NAP )។ ក្របខណ្ឌហិរញ្ញប្បទានផែនការជាតិបន្សាំ អាចទាញយកពីតំណភ្ជាប់នេះឬ www.camclimate.org.kh។ ភាសាខ្មែរអាចនឹងមាននៅខែមករា ឆ្នាំ២០១៨៕

| សកម្មភាពអាទិភាពជិតដំណាក់កាលអនុវត្ត | |
|---|---|
| គម្រោងបន្សាំនៅដំណាក់កាលរៀបចំ (ដោយមានកម្រិតខុសៗគ្នា) ដូច្នេះការអនុវត្តអាចធ្វើឡើងក្នុងរយៈពេលខ្លី (ប្រមាណមួយឆ្នាំ) ប្រសិនបើមានការអនុម័តលើសំណើមូលនិធិ។ | ប៉ាន់ស្មានថា ៣០% នៃសកម្មភាព NAP ស្ថិតនៅក្នុងក្រុមនេះ។ |
| **សកម្មភាពអាទិភាពនៅក្រោមដំណាក់កាលរៀបចំ** | |
| គម្រោងបន្សាំ ឯកសារគោលគំនិត ឬ គំនិត ដែលត្រូវរៀបចំពង្រីកបន្ថែម និង/ឬ ចាត់ចែងស្ថាប័នឱ្យមាននិរន្តរភាព ដើម្បីអាចធ្វើការអនុវត្ត (ក្នុងរយៈពេលមួយឆ្នាំ)។ | ប៉ាន់ស្មាន ៦០% នៃសកម្មភាពក្នុង NAP នឹងស្ថិតនៅក្នុងក្រុមនេះ។ |
| **សកម្មភាពអាទិភាពដែលរួមចំណែកបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់ NAP** | |
| កិច្ចផ្តួចផ្តើមអន្តរវិស័យនិង/ឬទូទាំងវិស័យ ដែលចាំបាច់ដើម្បីសម្រួលការអនុវត្ត NAP។ | ប៉ាន់ស្មាន ១០%នៃអាទិភាពសម្រាប់ NAP ស្ថិតនៅក្នុងក្រុមនេះ។ |

*កិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងផែនការកម្មវិធីវិនិយោគរបស់ក្រសួង ឆ្នាំ២០១៨ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ នៅក្រសួងសាធារណការ និងដឹកជញ្ជូន*

# សម្លេងពីមូលដ្ឋាន

## ភាពងាយរងគ្រោះនៃការចិញ្ចឹមជីវិតរបស់ឃុំចំនួន៤ នៅតំបន់រ៉ាមសារស្ទឹងត្រែង

តំបន់រ៉ាមសារស្ទឹងត្រែងត្រូវបានបង្កើតនៅខែមិថុនា ឆ្នាំ១៩៩៩ និងបានក្លាយជាតំបន់ស្ថិតនៅក្នុងបញ្ជីតំបន់ដីសើមអន្តរជាតិសម្រាប់អភិរក្សជីវៈចម្រុះជាសាកលទាំងការអភិរក្សនិងការប្រើប្រាស់។ ការគ្រប់គ្រងតំបន់រ៉ាមសារស្ទឹងត្រែង តម្រូវឱ្យមានតុល្យភាពរវាងប្រព័ន្ធអេកូឡូស៊ីការអភិរក្សប្រភេទសត្វ និងតម្រូវការរបស់សហគមន៍មូលដ្ឋាន។ ប្រជាពលរដ្ឋជាង១៣០០០នាក់ ដែលរស់នៅតំបន់នោះពឹងអាស្រ័យខ្លាំងលើតំបន់ដីសើមនេះ កំពុងមានការព្រួយបារម្ភកាន់តែខ្លាំងចំពោះការគំរាមកំហែងបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

នៅឆ្នាំ២០១៧ មន្ទីរបរិស្ថានខេត្តស្ទឹងត្រែង បានធ្វើការសិក្សាវាយតម្លៃភាពងាយរងគ្រោះនៃការចិញ្ចឹមជីវិតរបស់ប្រជាជននៅតំបន់រ៉ាមសារស្ទឹងត្រែង។ ការសិក្សានេះបានរកឃើញអំពីកត្តាដែលរួមចំណែកបង្កភាពងាយរងគ្រោះដល់ឃុំទាំងបួននៅតំបន់រ៉ាមសារ ហើយជាមូលដ្ឋានសម្រាប់អភិវឌ្ឍន៍ផែនការបន្សាំដែលនឹងជួយដល់មន្ទីរបរិស្ថានខេត្ត និងជាពិសេសមន្ត្រីគ្រប់គ្រងតំបន់រ៉ាមសារ អាចឆ្លើយតបនឹងបញ្ហាចម្បងនានាបង្កមកពីការប្រែប្រួលអាកាសធាតុ។

សន្ទស្សន៍ភាពងាយរងគ្រោះនៃជីវភាពរបស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ( IPCC ) មានផ្នែកចំនួន៣ ( ភាពប្រឈម ភាពរស់ និងសមត្ថភាពបន្សាំ ) ត្រូវបានប្រើប្រាស់នៅក្នុងការសិក្សានេះ ដើម្បីវាយតម្លៃភាពងាយរងគ្រោះនៃជីវភាពក្នុងចំណោមគ្រួសារសំណាកចំនួន៣៥០គ្រួសារ ក្នុងនោះស្ត្រីជាមេគ្រួសារចំនួន ១០៥គ្រួសារ នៅក្នុងឃុំទាំងបួនរបស់តំបន់នោះ គឺឃុំព្រះរំកិល, កោះស្នែង អូស្វាយ និងសាមគ្គី។ ម៉ូដែលអាកាសធាតុចំនួនពីរ ត្រូវបានប្រើជាផ្នែកសំខាន់នៃភាពប្រឈម។

ការសិក្សាបានរកឃើញថាឃុំទាំងបួនគឺងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ ក្នុងនោះឃុំព្រះរំកិលនិងឃុំកោះស្នែងងាយរងគ្រោះខ្លាំងបំផុត។ ស្ត្រីជាមេគ្រួសារ មានភាពងាយរងគ្រោះនឹងការប្រែប្រួលអាកាសធាតុជាងបុរស ដោយសារតែសមត្ថភាពសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ភាពពឹងផ្អែកលើសេដ្ឋកិច្ចសង្គម យុទ្ធសាស្ត្រជីវភាព និងបណ្តាញសង្គមរបស់ពួកគាត់នៅទាប។ ឃុំទាំងនេះគឺងាយរងគ្រោះដោយសារទឹកជំនន់ ដោយសារតែភាពប្រឈមខ្ពស់ កង្វះខាតប្រព័ន្ធផ្តល់ព័ត៌មាន ហើយការត្រៀមបង្ការមានកម្រិតទាប។

ការសិក្សាបានរកឃើញថាប្រជាជនភាគច្រើនដែលរស់នៅក្នុងតំបន់រ៉ាមសារមិនធ្លាប់ទទួលការបណ្តុះបណ្តាល និងមិនដឹងពីរបៀបឆ្លើយតបនឹងស្ថានភាពលំបាកទាំងនេះឡើយ។ ឧទាហរណ៍ ភាពលំបាកក្នុងការ



*បទសម្ភាសន៍មួយជាមួយមេគ្រួសារជាស្ត្រីនៅឃុំព្រះរំកិល ខេត្តស្ទឹងត្រែង នាខែវិច្ឆិកា ឆ្នាំ២០១៧*




*ទីតាំងសិក្សានៃតំបន់រ៉ាមសារស្ទឹងត្រែង*

ទទួលបានសេវាថែទាំងសុខភាពទប់ស្កាត់ជំងឺគ្រុនចាញ់និងគ្រុនឈាម។ ទោះបីជាមានផលប៉ះពាល់បំផ្លិចបំផ្លាញដំណាំម្តងហើយម្តងទៀតពីទឹកជំនន់ ក៏ប្រជាជនមិនបានកែប្រែបច្ចេកទេសធ្វើកសិកម្មដែលមានភាពធន់ ឬប្រើប្រាស់យុទ្ធសាស្ត្រចិញ្ចឹមជីវិតប្រសើរជាងមុនឡើយ។

ដើម្បីកាត់បន្ថយភាពងាយរងគ្រោះប្រកបដោយប្រសិទ្ធភាព ការសិក្សានេះបានដាក់ចេញនូវអនុសាសន៍សំខាន់ៗរួមមាន៖

- បង្កើតប្រព័ន្ធផ្តល់ព័ត៌មាន ដូចជាការប្រើប្រាស់វិទ្យុសហគមន៍ ការឆ្លើយតបបន្ទាន់ និងផែនការវាយតម្លៃ (ឧ. ផ្លូវទៅទីទួលនិងជម្រកសុវត្ថិភាព ក្រុមជួយសហគមន៍ជួយជនងាយរងគ្រោះ)
- ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការគាំពារសុខភាព។ ឧ. សុវត្ថិភាពម្ហូបអាហារ អនាម័យ និងជំនួយបឋម។
- បង្កើតផែនការគ្រប់គ្រងគ្រោះមហន្តរាយដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត។
- បញ្ចូលគ្រួសារទាំងជាបុរស ស្ត្រី និងជនងាយរងគ្រោះ ក្នុងការរៀបចំផែនការកាត់បន្ថយហានិភ័យ។

ការសិក្សានេះ បានផ្តល់នូវព័ត៌មានអំពីកម្រិតនិងមូលហេតុនៃភាពងាយរងគ្រោះរបស់ឃុំក្នុងតំបន់រ៉ាមសារ ហើយអនុសាសន៍ទាំងនេះអាចប្រើប្រាស់សម្រាប់រៀបចំផែនការបន្សាំនឹងប្រែប្រួលអាកាសធាតុ។ ជាលទ្ធផល មេរៀនមួយចំនួនដែលទទួលបានពីការអនុវត្តគម្រោងនៅក្នុងតំបន់នេះ អាចប្រើប្រាស់សម្រាប់គ្រប់គ្រងសហគមន៍ ដូចជាការគ្រប់គ្រងទឹក និងបច្ចេកទេសកសិកម្ម ជាដើម៕

## ការច្នៃប្រឌិតថ្មីនៃឡជីវឧស្ម័នខ្នាតមធ្យមសម្រាប់បរិស្ថានស្អាត

ប្រទេសកម្ពុជាមានសក្តានុពលបច្ចេកទេសច្រើនសម្រាប់ឡជីវឧស្ម័នលក្ខណៈគ្រួសាររហូតដល់៨៩០០០០គ្រួសារនិងឡជីវឧស្ម័នលក្ខណៈពាណិជ្ជកម្មខ្នាតមធ្យមនិងខ្នាតធំ ជាច្រើនរយកន្លែង។ បច្ចេកវិទ្យានេះរួមចំណែកកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដោយបានបំលែងមេតានចេញពីលាមកសត្វ ទៅជា ជីវឧស្ម័នដែលអាចដុតបង្កើតជាថាមពល។ ទោះជាយ៉ាងណា ឡជីវឧស្ម័នលក្ខណៈពាណិជ្ជកម្មមិនទាន់ត្រូវបានលើកកម្ពស់ឱ្យបានទូលំទូលាយនៅកម្ពុជានៅឡើយទេ។

ឡជីវឧស្ម័នខ្នាតមធ្យមដែលមានបច្ចេកវិទ្យាឆ្លាតខាងបរិស្ថាន កំពុងមានការសិក្សានិងសាកល្បងនៅកម្ពុជាចាប់តាំងពីខែកក្កដា ឆ្នាំ២០១៦ ដោយកម្មវិធីឡជីវឧស្ម័នជាតិ គាំទ្រហិរញ្ញវត្ថុពីនាយកដ្ឋានប្រែប្រួលអាកាសធាតុនិងកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា(CCCA)។ គោលដៅចម្បងរបស់ឡជីវឧស្ម័នប្រភេទនេះ គឺដើម្បីបំលែងការបញ្ចេញ



*ឡជីវឧស្ម័នខ្នាតមធ្យមផ្ទុកលាមកជ្រូក ក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ នាខែធ្នូ ឆ្នាំ២០១៦*

ឧស្ម័នពីលាមកសត្វដ៏ច្រើនទៅជាថាមពលជីវៈសម្រាប់ផលិតអគ្គីសនី និងដើម្បីកែលម្អសុខភាពបសុសត្វ ដូចជា ការលុបបំបាត់ក្លិនស្អុយ និងកង្វះទីតាំងបង្ហូរលាមកសត្វចូលក្រោមដីឬស្រះ។ សកម្មភាពមួយចំនួនរបស់កម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិ រួមមាន៖

១) ការរៀបចំសិក្សាអំពីគំរូឡខ្នាតមធ្យម
២) ការជ្រើសរើសម្ចាស់កសិដ្ឋានដោយស្ម័គ្រចិត្តដើម្បីសាកល្បង
៣) ការសាងសង់ឡជីវឧស្ម័នដែលបំពាក់បច្ចេកវិទ្យាសមស្របទៅនឹងម៉ាស៊ីនផលិតអគ្គីសនី
៤) ការត្រួតពិនិត្យនិងវាយតម្លៃត្រឹមត្រូវទៅលើគំរូសាកល្បងនេះ។

បច្ចុប្បន្ននេះ កម្មវិធីឡជីវឧស្ម័នជាតិ កំពុងសាងសង់សាកល្បងឡជីវឧស្ម័នខ្នាតមធ្យមនេះ នៅក្នុងកសិដ្ឋានចិញ្ចឹមជ្រូកចំនួនបីកន្លែងផ្សេងគ្នាក្នុងខេត្តកំពង់ស្ពឺ ដែលកែច្នៃលាមកជ្រូកសរុបប្រមាណ៦១៣១តោន ដោយមានសក្តានុពលកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិកសមមូលប្រមាណ៣៤០០ តោនក្នុងមួយឆ្នាំ។

លោក ឃុត ថុង ម្ចាស់កសិដ្ឋានចិញ្ចឹមជ្រូកសរុប ១២០០ក្បាល នៅស្រុកបាសេដ្ឋ បានស្ម័គ្រចិត្តដំឡើងឡជីវឧស្ម័នខ្នាតមធ្យមនេះក្នុងឆ្នាំ២០១៧។ លោកតុង បានបន្តថា “ដោយមានជំនួយហិរញ្ញវត្ថុពីកម្មវិធី [NBP] ខ្ញុំបានបំពាក់ម៉ាស៊ីនភ្លើងមួយគ្រឿងដែលមានសមត្ថភាពផលិតអគ្គីសនី ៦០kVA អាចជួយសន្សំសំចៃថ្លៃចំណាយអគ្គីសនីប្រចាំខែប្រហែល ៣០% ទៅ ៥០%”។

លោកតុងក៏បានចាប់អារម្មណ៍ថា ឡជីវឧស្ម័នេះបានដោះស្រាយបញ្ហាចម្បងមួយរបស់គាត់ គឺការខ្វះកន្លែងបង្ហូរលាមកសត្វពីកសិដ្ឋានរប ស់គាត់។ គាត់និងកសិករជិតខាង បានទទួលការប ណ្តុះបណ្តាលពីរបៀបប្រើប្រាស់ជីឡជីវឧស្ម័នដែលជាអនុផលនៃដំណើរការផលិត

## ការច្នៃប្រឌិតថ្មីរបស់ឡជីវឧស្ម័នខ្នាតមធ្យមសម្រាប់ ...

តពីទំព័រទី៥



សួនបង្ហាញសាកល្បងកម្មដោយប្រើប្រាស់ជីឡជីវឧស្ម័ននៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ នាខែសីហា ឆ្នាំ២០១៧

ជីវឧស្ម័ន សម្រាប់បង្កើនទិន្នផលដំណាំនិងបង្កើនជីវជាតិដីបានយូរអង្វែង។ ពួកគាត់បានយល់ដឹងថាជីឡជីវឧស្ម័ន គឺជាជីមានសុវត្ថិភាពសរីរាង្គ និងរាវ ដែលអាចប្រើបានចំពោះដំណាំ និងដើមឈើគ្រប់ប្រភេទ ហើយដើរតួនាទីសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវរចនាសម្ព័ន្ធដី និងជីវជាតិដី ស្ទើរតែគ្រប់ប្រភេទ។

បច្ចេកវិទ្យាជីវឧស្ម័នខ្នាតមធ្យមកំពុងបង្កើតការចាប់អារម្មណ៍ខ្លាំងពីម្ចាស់កសិដ្ឋានចិញ្ចឹមជ្រូក ព្រោះវាអាចកាត់បន្ថយថ្លៃផលិតកម្ម (ឧ. កាត់បន្ថយថ្លៃចំណាយថាមពល ឬជី)។ ក្រៅពីនេះ បច្ចេកវិទ្យានេះរួមចំណែកកាត់បន្ថយការបញ្ចេញកាបូនពីខ្សែចង្វាក់សកម្មភាពសេដ្ឋកិច្ចប្រភេទនេះ។ ទោះជាយ៉ាងក្តី កម្មវិធីនៅតែត្រូវការកិច្ចគាំទ្របន្ថែមទៀត ដើម្បីពង្រីកវិសាលភាពនៃបច្ចេកវិទ្យានេះទៅកាន់កន្លែងផ្សេង និងបង្កើនអត្រាទទួលយកបច្ចេកវិទ្យាដែលបច្ចេកកាបូនទាបនិងមិនប៉ះពាល់បរិស្ថាន៕

## ការចេញផ្សាយបន្ទាប់...

### ការបញ្ចូលឯកសារប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សាអប់រំថ្នាក់ជាតិ



ឯកសារអប់រំស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់មធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០ ១១ និង១២) បានបង្រៀនសាកល្បងនៅក្នុងវិទ្យាល័យចំនួន១០ ហើយគ្រោងនឹងប្រកាសដាក់ឱ្យប្រើប្រាស់ផ្លូវការនៅខែមិថុនា ឆ្នាំ២០១៨។ ឯកសារអប់រំនេះ ត្រូវបានរៀបចំដោយក្រុមបច្ចេកទេសនៃនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា ដែលគាំទ្របច្ចេកទេសដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុ និងកម្មវិធីCCCA។ សៀវភៅនេះ មាន៣កម្រិតផ្សេងៗគ្នា ដើម្បីលើកកម្ពស់ចំណេះដឹងរបស់មន្ត្រីអប់រំ គ្រូបង្រៀន សិស្សានុសិ្សតអំពីការប្រែប្រួលអាកាសធាតុតាមរយៈការបញ្ចូលខ្លឹមសារប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សាអប់រំថ្នាក់ជាតិ។ ការងារនេះកំពុងត្រូវបានអនុវត្តដោយនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដែលជាផ្នែកមួយនៃគម្រោង "ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុក្នុងវិស័យអប់រំ"៕

## ឯកសារបោះពុម្ពផ្សាយនាពេលខាងមុខ




ការពិនិត្យចំណាយសាធារណៈពាក់ព័ន្ធអាកាសធាតុ(CPER) ឆ្នាំ២០១៦ដែលសិក្សាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តល់នូវបច្ចុប្បន្នភាពលើការចំណាយសាធារណៈពាក់ព័ន្ធការប្រែប្រួលអាកាសធាតុសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៦ដោយវិភាគទិន្នន័យចំណាយសាធារណៈសម្រាប់ក្រសួងនិងស្ថាប័ន១៥ដែលបានរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ការសិក្សាបង្ហាញថាការចំណាយពាក់ព័ន្ធការប្រែប្រួលអាកាសធាតុបានបន្តធ្លាក់ចុះចំនួន១២% នៅឆ្នាំ២០១៦ បន្ទាប់ពីការធ្លាក់ចុះ៩% នៅឆ្នាំ២០១៥ ដោយសារតែការកាត់បន្ថយហិរញ្ញប្បទានអាកាសធាតុយ៉ាងលឿនពីប្រភពខាងក្រៅ(២១%) ដែលច្បាស់ជាងនេះគឺការកាត់បន្ថយជំនួយអភិវឌ្ឍន៍ផ្លូវការជារួម (រួមទាំងអង្គការក្រៅរដ្ឋាភិបាល) ចំពោះកម្ពុជាប្រហែល១០% នៅឆ្នាំ២០១៦។ CPER ២០១៦ នឹងបោះពុម្ពផ្សាយនៅខែមករា ឆ្នាំ២០១៨៕

## ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ

ខែមករា សិក្ខាសាលាផ្សព្វផ្សាយស្តីពីយន្តការឥណទានកាបូនរួមគ្នាក្នុងបច្ចេកវិទ្យាបញ្ចេញកាបូនទាប

ខែមករា វគ្គបណ្តុះបណ្តាលជាតិស្តីពីការធ្វើប្រើប្រាស់ឧបករណ៍ ALU សម្រាប់ចងក្រងនិងវិភាគទិន្នន័យការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីវិស័យកសិកម្ម ការប្រើប្រាស់ដី នៅកម្ពុជា

ខែកុម្ភៈ ការចុះវាយតម្លៃការបង្រៀនឯកសារអប់រំស្តីពីការប្រែប្រួលអាកាសធាតុ នៅក្នុងវិទ្យាល័យចំនួន១០។

ខែកុម្ភៈ កិច្ចប្រជុំលើកទី១២នៃក្រុមប្រឹក្សាភិបាលកម្មវិធីCCCA

ខែមីនា សិក្ខាសាលាពិគ្រោះថ្នាក់ជាតិស្តីពីឯកសារអប់រំស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់មធ្យមសិក្សាទុតិយភូមិ

*សម្រាប់ព័ត៌មានទាក់ទងនឹងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឬឯកសារបោះពុម្ពថ្មីៗ សូមតាមដានគេហទំព័រ www.camclimate.org.kh*

**គាំទ្រដោយ**

កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា
CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Ministry of Environment
Supported by: European Union, UNDP (Empowered lives. Resilient nations.), SWEDEN

**ទំនាក់ទំនង**

នាយកដ្ឋានប្រែប្រួលអាកាសធាតុ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
ស្ថិតក្នុងក្រសួងបរិស្ថាន អគារមរតកតេជោ ដីឡូត៍លេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ +៨៥៥ ២៣ ៦៤០ ៣៨៣៣ | សារអេឡិចត្រូនិច៖ admin@camclimate.org.kh
គេហទំព័រ៖ www.camclimate.org.kh